00143933

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០២/១៤-០៨-២០០៦-អវតក/អបជ —71—C10

អង្គបុរេជំនុំជម្រះ

ចំពោះមុខ:
ចៅក្រម ប្រាក់ គីមសាន
ចៅក្រម ហួត វុទ្ធី
ចៅក្រម Rowan Downing
ចៅក្រម ន័យ ថុល
ចៅក្រម Katinka Lahuis

កាលបរិច្ឆេទ: ២៦ តុលា ២០០៧

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 30 ខែ(Month/Mois) OCT
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier M Edmonds

---

សាធារណៈ:
# សេចក្ដីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សេចក្ដីសន្និដ្ឋានតបទៅនឹងសារណារបស់សាធារណជន

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH

ORIGINAL DOCUMENT
RECEIVED ON 26 OCT 2007
AT 14:40.
BY MAUREEN EDMONDS
M Edmonds
CASE FILE OFFICER.

**ជនត្រូវចោទ**
កាំង ហ្គេកអ៊ាវ

**មេធាវីការពារក្ដី**
ការ សាវុត្ថ
François ROUX

# អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អវតក"

**បានឃើញ** សំណើសុំការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣ ខែ តុលា ២០០៧ ទៅនឹងសារណារបស់សាធារណៈជន ដែលបានដាក់ចូលមកក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់មេធាវីជនត្រូវចោទ **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន

**បានឃើញ** សំណើសុំការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋានតបរបស់មេធាវី ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៧ ទៅនឹងសារណារបស់សាធារណៈជន ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ដែលចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧

**យល់ឃើញថា** ដោយអនុលោមតាមសេចក្តីជូនដំណឹងជាសាធារណៈ ដែលចេញដោយប្រធានអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០៧ សារណាសាធារណជនចំនួន ៦ ត្រូវបានដាក់ជូនមកអង្គបុរេជំនុំជម្រះ ហើយនាពេលនេះ មានជាភាសាអង់គ្លេស និង ភាសាខ្មែរ

**យល់ឃើញថា** ការបកប្រែជាភាសាបារាំង នៃសារណារបស់សាធារណជនកំពុងតែដំណើរការ

**ពិចារណាទៅលើ** វិធាន ៣៣(២) នៃវិធានផ្ទៃក្នុង ដែលចែងថា "សារណាដែលធ្វើឡើងក្រោមវិធាននេះ ត្រូវប្រគល់ទៅអោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធ ។ ក្រឡាបញ្ជីត្រូវប្រគល់ឯកសារថតចម្លងមួយច្បាប់ទៅអោយសហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីដទៃទៀត ដើម្បីមានឱកាសធ្វើការឆ្លើយតប"

**ដូច្នេះអនុញ្ញាត** លើសំណើរបស់ភាគីទាំងពីរ ក្នុងការដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសាធារណារបស់សាធារណជន ប្រសិនបើមានតម្រូវការ ដោយអនុលោមតាម វិធាន ៣៣(២) ហើយសារណាទាំងនោះ នឹងត្រូវផ្តល់អោយជាភាសាអង់គ្លេស និង ភាសាខ្មែរ ជាមួយនឹងសេចក្តីសម្រេចនេះ និង ជាភាសាបារាំងនៅពេលដែលមានការបកប្រែរួចរាល់

**បង្គាប់** អោយរាល់សេចក្តីសន្និដ្ឋានតបទាំងអស់ ត្រូវដាក់មកត្រឹមថ្ងៃ ច័ន្ទ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧

**ជ.អង្គបុរេជំនុំជម្រះ**

**ប្រធាន**

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

**ប្រាក់ គឹមសាន**